# ឧត្តមភាពស្ត្រីតាមរយៈគំណាលកថាប្រជាប្រិយមួយចំនួន
## (តពីលេខមុន)

*ដោយៈ* **លោកស្រីបណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

### ២.៣- ឧត្តមភាពស្ត្រីក្នុងស្មារតីសន្តិភាព

*ក្នុងសង្គមជាតិមួយ មនុស្សគ្រប់រូបរមែងតែងតែប្រាថ្នាចង់បាននូវសេចក្តីសុខ សន្តិភាព ភាពសុខដុមរមនាប្រកបដោយសុភមង្គល និងការអភិវឌ្ឍចម្រើនរុងរឿង។ សន្តិភាពសំដៅដល់សេចក្តីសុខ សេចក្តីស្ងប់ មិនមានជម្លោះកើតឡើង មិនថាក្នុងសង្គមគ្រួសារ ឬនៅក្នុងសង្គមជាតិនោះទេ។ ធម្មជាតិនៃមនុស្ស តែងតែប្រាថ្នាចង់បាននូវសន្តិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។ ដើម្បីឱ្យមានសន្តិភាពទាល់តែមនុស្សមានសីលធម៌ និងគុណធម៌នៅក្នុងខ្លួន ដោយការគោរពសិទ្ធិគ្នាទៅវិញទៅមក មិនបំពានផលប្រយោជន៍រវាងគ្នានិងគ្នា។ ចំណែកនៅក្នុងសង្គមគ្រួសារក៏ដូច្នោះដែរ ដើម្បីឱ្យគ្រួសារមួយមានសន្តិភាពទាល់តែសមាជិកក្នុងគ្រួសារ ពិសេសស្វាមី និងភរិយាចេះយោគយល់អធ្យាស្រ័យ គោរពសិទ្ធិនិងតួនាទីគ្នា មានភាពស្មោះត្រង់ មិនបង្កជម្លោះជាដើម។ បើនិយាយអំពីការគោរពសិទ្ធិនៅក្នុងគ្រួសារវិញនោះ គឺជាប់ទាក់ទងទៅនឹងការគោរពចំពោះស្ត្រី ឱ្យតម្លៃស្ត្រី។ ការឱ្យតម្លៃចំពោះស្ត្រីបានចូលរួមចំណែកក្នុងការបណ្តុះនូវស្មារតីសន្តិភាពដល់សង្គមគ្រួសារ និងសង្គមជាតិ ដ្បិតថាការគោរពចំពោះស្ត្រី ជាការឱ្យតម្លៃស្ត្រី។ ដូច្នេះបើស្វាមីចេះឱ្យតម្លៃដល់ភរិយា លើកតម្កើងភរិយានោះនឹងគ្មានអំពើហិង្សានិងការរើសអើងចំពោះស្ត្រីឡើយ។ តាមរយៈការឱ្យតម្លៃចំពោះស្ត្រី បានជួយឱ្យបុរសនិងស្ត្រីមានសេចក្តីសុខ និងសុភមង្គលក្នុងគ្រួសារបានយូរអង្វែង។ បើសង្គមគ្រួសារគ្មានអំពើហិង្សា គ្រួសារមានតែសេចក្តីសុខ សង្គមជាតិក៏មាន*

តែភាពរីកចម្រើនទៅមុខៗ ស្ត្រីជាអ្នកនាំសារសន្តិភាព ជាអ្នកនាំមកនូវភាពស្ងប់សុខដល់គ្រួសារ និងសង្គមៗ ជាក់ស្តែងនៅក្នុងរឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ ក៏បានបង្ហាញឱ្យឃើញពីការប្រកាន់ខ្ជាប់នូវស្មារតីសន្តិភាពនៅក្នុងគ្រួសារតាមរយៈតួអង្គស្ត្រីគ្រប់លក្ខណ៍ៗ នៅក្នុងសាច់រឿងបានបង្ហាញថា ទោះបីជាប្តីជាមនុស្សខ្ជិលច្រអូស មិនធ្វើការងាររកស៊ីអ្វីសោះ គិតតែពីដេកចាំឱ្យនាងបម្រើគ្រប់បែបយ៉ាងក៏ដោយ ក៏ស្ត្រីគ្រប់លក្ខណ៍នៅតែមិនរករឿងឈ្លោះប្រកែក ឬប្រើពាក្យមិនសមរម្យជាមួយនឹងប្តីសោះឡើយៗ បើទោះជានាងចង់ប្រើប្តីឱ្យទៅកាប់ឈើនៅក្នុងព្រៃ ក៏នាងនៅតែរក្សាពាក្យពីរោះផ្អែមល្ហែមនិងថ្នមចិត្តប្តីជានិច្ច សូម្បីតែពេលព្រឹកក៏មិនដែលហ៊ានដាស់ប្តីឱ្យក្រោកដែរៗ លុះពេលបុរសកម្ជិលបានចូលទៅក្នុងព្រៃម្តងជាពីរដង ប៉ុន្តែមិនបានផលអ្វី ក៏ស្រីគ្រប់លក្ខណ៍នៅតែគោរពប្រណិប័តន៍ប្តីដោយរៀបបាយរៀបទឹក រហូតដល់យកទឹកមកលាងជើងឱ្យប្តីដដែល (ប្រពន្ធក្រោកពីយប់ដាំបាយវេចដាកញ្ចប់មានទាំងដីងពូថៅផងៗ បុរសកម្ជិលដេកទាល់តែថ្ងៃរះ ប្រពន្ធពុំហ៊ានដាស់ ចាំឱ្យក្រោកខ្លួនឯង ដល់ក្រោកហើយ ប្រពន្ធដងទឹកឱ្យលុបមុខ រួចស្រេចនាងក៏ហុចស្លាបារីទៅឱ្យប្តីនឹងបាយកញ្ចប់ព្រមទាំងគ្រឿងប្រដាប់)[១] ពោលគឺនាងជាស្ត្រីគ្រប់លក្ខណ៍ដែលរក្សាបាននូវសេចក្តីសុខក្នុងគ្រួសារ ទោះបីជីវភាពគ្រួសារមានការលំបាកយ៉ាងណាក៏ដោយ ក៏នាងនៅតែរក្សាជំហជាប្រពន្ធល្អ មិនបង្កជម្លោះជាមួយនឹងប្តីដែលជាឥរិយាបថក្នុងការរក្សានូវសុខសន្តិភាពសម្រាប់គ្រួសារៗ

ចំណែករឿងមាយើង ក៏បានបង្ហាញពីស្មារតីសន្តិភាពរបស់ស្ត្រីគ្រប់លក្ខណ៍ជាភរិយារបស់នាយកេត្រាផងដែរៗ ទោះបីប្តីរបស់ខ្លួនបានបណ្តេញខ្លួនឱ្យចុះចេញពីសំពៅដោយគ្មានអាណិតអាសូរដល់រូបនាងសូម្បីបន្តិច និងថែមទាំងសុំដូរនាងជាមួយប្រពន្ធចៅមាយើងក៏ដោយ ក៏នាងនៅតែរក្សាជំហររបស់ខ្លួនមិនប្រកែកតវ៉ា ឬបង្កជម្លោះជាមួយនឹងនាយកេត្រានោះទេ ដោយរូបនាងសុខចិត្តចាកចេញពីសំពៅទៅរស់

[១] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ១* រឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ ទំ.៩១ៗ

នៅជាមួយនឹងថៅមាណពកម្សត់ដោយស្ម័គ្រចិត្ត និងមិនបង្កជាជម្លោះឬបញ្ហាអ្វីឡើយ សូម្បីតែរបស់ទ្រព្យបន្តិចបន្តួចក៏នាងមិនយកដែរ ដូចមានបញ្ជាក់ក្នុងរឿងថា៖ ទើបនាងឆ្លើយទៅ កាន់នាយសំពៅ ជាប្ដីអាត្មា ពាក្យខ្ញុំទ្រគោះ លើសលស់ត្រង់ណា ក៏ដល់អ្នកជា ប្ដីពុំចូលចិត្ត។ នឹងយកខ្ញុំទៅ ដូរមាណពនៅ កាន់ឈ្នាងជញ្ជាត់ បើអ្នកដូរទៅ ខ្ញុំទៅនឹងគាត់ ខ្ញុំសោតគ្មានមាត់ ប្រកែកថាអ្វី។ [២]

សរុបមក រឿងទាំងនេះ គឺជាការបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ពីគុណតម្លៃរបស់ស្ត្រីដែលស្រឡាញ់នូវសេចក្ដីស្ងប់ ស្រឡាញ់សន្តិភាព មិនចង់ឱ្យមានជម្លោះកើតឡើងឡើយ។

### ២.៤- ឧត្តមស្ត្រីក្នុងការអប់រំបណ្ដុះសីលធម៌ និងគុណធម៌

សីលធម៌ និងគុណធម៌ គឺជាធម៌ដ៏ប្រពៃដែលមនុស្សមិនអាចខ្វះបាននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ សីលធម៌ និងគុណធម៌ប្រៀបបាននឹងគ្រឿងអលង្ការដ៏មានតម្លៃបំផុតសម្រាប់ញ៉ាំងឱ្យការរស់នៅរបស់មនុស្សមានកិត្តិយស សេចក្ដីថ្លៃថ្នូរ និងការគោរពពីសំណាក់មនុស្សនៅជុំវិញខ្លួន។ ទោះបីជាអ្នកស្ថិតក្នុងឋានៈណា មានទ្រព្យសម្បត្តិ មានបុណ្យសក្តិខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ តែបើបុគ្គលនោះគ្មានសីលធម៌និងគុណធម៌នោះទេ ក៏គេពុំអាចក្លាយជាមនុស្សថ្លៃថ្នូរនៅក្នុងសង្គមបានដែរ។

បើនិយាយអំពីបញ្ហាសីលធម៌ វាជាធម៌មួយដ៏ប្រពៃដែលមនុស្សត្រូវតែប្រកាន់ខ្ជាប់នៅក្នុងខ្លួន។ មនុស្សដែលមានសីលធម៌ត្រូវបានគេចាត់ទុកថាជាឧត្តមបុគ្គលដែលរស់នៅក្នុងសង្គម។ ក្នុងការរស់នៅមនុស្សគ្រប់រូបត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ប្រាំយ៉ាងរួមមាន សីលធម៌ផ្ទាល់ខ្លួន សីលធម៌គ្រួសារ សីលធម៌វិជ្ជាជីវៈ សីលធម៌សង្គម និងសីលធម៌ពិភពលោក ។ បើនិយាយពីសីលធម៌គ្រួសារ គឺមានន័យថា ការស្គាល់នូវកាតព្វកិច្ចខ្លួន ដែលអាចជាឪពុកម្ដាយ ជាកូន ជាស្វាមី ជាភរិយា ដែលចិញ្ចឹមបីបាច់ថែរក្សាកូនឬសមាជិកគ្រួសារបានល្អ ពិសេសគឺការបំពេញបុគ្គលិកលក្ខណៈជាឪពុកម្ដាយ

[២] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.២២។

ប្រកបដោយព្រហ្មវិហារធម៌ ជាកូនកត្តញ្ញូ ជាស្វាមីឬជាភរិយាល្អ ទាំងការគោរព ប្រណិប័តន៍ ក៏ដូចជាការជួយទំនុកបម្រុង។

បើផ្អែកតាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនាក្នុងការអប់រំសីលធម៌នារី គឺតម្រូវឱ្យភរិយាចេះគោរពនូវតួនាទីរបស់ខ្លួនដែលមាន៥ប្រការគឺ៖ ចេះចាត់ចែងការងារផ្ទះ សង្គ្រោះញាតិទាំងសងខាង ថែទាំទ្រព្យសម្បត្តិដែលប្តីរកបាន មិនក្បត់ផិត ឧស្សាហ៍ព្យាយាមមិនខ្ជិលច្រអូស។ យ៉ាងណាមិញ តាមរយៈរឿងមាយើង បានបង្ហាញឱ្យឃើញពីសីលធម៌ ចរិយាសាស្ត្ររបស់នារីខ្មែរតាមរយៈតួអង្គស្ត្រីគ្រប់លក្ខណ៍ ដែលជាស្ត្រីគំរូមួយរូបគួរឱ្យគោរពកោតសរសើរ។ ម្យ៉ាងទៀតបើតាមរយៈតួអង្គស្រីគ្រប់លក្ខណ៍បានបង្ហាញពីសីលធម៌របស់ស្ត្រីក្នុងការរស់នៅនិងការបំពេញតួនាទីជាភរិយាដ៏ប្រពៃនៃចៅមាយើង។ តួអង្គស្ត្រីគ្រប់លក្ខណ៍ជាស្ត្រីដែលប្រកបដោយសីលធម៌ខ្ពស់ ចេះគោរពប្រណិប័តន៍ស្វាមី យល់កាលៈទេសៈ ចេះបត់បែន ចេះគោរពស្រឡាញ់ញាតិជិតខាង និងមានភក្តីភាពចំពោះស្វាមី ទោះក្នុងស្ថានភាពបែបណាក៏ដោយ ដែលស្ត្រីគ្រប់រូបគួរយកគំរូតាម។ ប៉ុន្តែតាមរយៈសាច់រឿងដដែលនេះ ក៏បានបង្ហាញពីការធ្លាក់ចុះនូវតម្លៃសីលធម៌ស្ត្រីតាមរយៈតួអង្គនាងកញ្ញើធ្នុះ ដែលជាស្ត្រីមួយរូបប្រព្រឹត្តប្រាសចាកសីលធម៌នារីខ្មែរ មានចិត្តផិតក្បត់ចំពោះចៅមាណព គ្រាន់តែឃើញនាយកេត្រាដែលជាអ្នកមានទ្រព្យភ្លាម ក៏មានចិត្តវៀចវេរពីចៅមាណព មិនគោរពតួនាទីជាភរិយា សុខចិត្តចាកចោលចៅមាណពដែលជាប្តីទៅរស់នៅជាមួយនាយកេត្រា រហូតជួបនូវលទ្ធផលចុងក្រោយដែលកើតចេញពីទង្វើរបស់ខ្លួននោះ គឺត្រូវរលាយហិនហោចទ្រព្យសម្បត្តិទាំងអស់ ដូចមានសេចក្តីបញ្ជាក់ដូច្នេះថា៖ ថានាងប្អូនស្និទ្ធ ស្នេហ៍ស្នាលចូលចិត្ត ព្រមមូលនឹងបង ឬមួយពុំមូល ពុំចូលចិត្តបង ចូរចៅសារសង ឥឡូវនេះណា។ ឯមេកញ្ញើ ធ្នុះអរលលើ ចង់នាយនាវា សើចហើយញញឹម មើលចុងនេត្រា ឱនហើយទើបថា គូពីព្រេងហោង។[៣] នេះបញ្ជាក់ពីការធ្លាក់ចុះនៃតម្លៃសីលធម៌ស្ត្រី ជាគំរូមិនល្អ ដែលមិនគួរកើត

[៣] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.២៣។

មានក្នុងសង្គម និងមិនត្រូវយកគំរូតាមនោះទេ។ ឥរិយាបទបែបនេះវាជាបុព្វហេតុដែលនាំឱ្យគ្រួសារជួបប្រទះតែរឿងអពមង្គលដោយសារស្នាដៃស្ត្រីខាតលក្ខណ៍។

នៅក្នុងរឿងដដែលនេះ ក៏បានអប់រំណែនាំអំពីសីលធម៌របស់ស្ត្រីក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គឺការចេះប្រាស្រ័យទាក់ទងជាមួយញាតិមិត្តជិតខាងទាំងឡាយផង។ ជាក់ស្តែង កាលពីប្រពន្ធចាស់របស់មាយើងជាស្ត្រីខាតលក្ខណ៍ នាងមិនចេះរាប់ញាតិជិតខាង នាងធ្វើឱ្យគេស្អប់ខ្ពើម មិនចូលចិត្តរស់នៅគ្មានញាតិផៅស្រឡាញ់រាប់រក ខណៈពេលដែលបានប្រពន្ធក្រោយជាស្ត្រីគ្រប់លក្ខណ៍ មកធ្វើជាប្រពន្ធរបស់មាណព នាងតែងតែមានអធ្យាស្រ័យល្អជាមួយញាតិទាំងឡាយ។ នាងត្រូវបានអ្នកភូមិគោរពស្រឡាញ់ពេញចិត្ត និងរាប់អានជួយយកអាសារគ្រប់ៗគ្នា។ ដូចមានការបរិយាយក្នុងផ្ទៃរឿងថា៖ នាងយកត្រីនោះ ឱ្យប្តីនាងស្ងោះជូនចែកគ្រប់គ្នា តិចៗគ្រប់មុខ អ្នកស្រុកនៅនា ព្រៀងលានស្គាល់គ្នា ខេត្តខាងលំនៅ។ ប្តីសោតទៅស្ងោះ ដោយប្រពន្ធនោះបង្គាប់ប្រដៅ កាលនោះព្រៀងលានខាងឋានលំនៅ សឹងគិតថាចៅ នេះដែលឯណា។[៤]

សីលធម៌ក្នុងការរស់នៅប្រាស្រ័យទាក់ទងគ្នា វាជារឿងសំខាន់ព្រោះមនុស្សម្នាក់ៗមិនអាចរស់នៅតែម្នាក់ឯងបាននោះឡើយ គឺរមែងតែងតែត្រូវពឹងពាក់អាស្រ័យមានទំនាក់ទំនងជាមួយញាតិសន្តាន និងអ្នកដទៃ ដែលនេះជាការអប់រំសីលធម៌ក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងសង្គម។ តាមរយៈ ***រឿងស្ត្រីពិត ម្តាយពិត ឪពុកពិត*** ក៏បានបង្ហាញពីការធ្លាក់ចុះនូវតម្លៃសីលធម៌នារីផងដែរ។ ការធ្លាក់ចុះនោះបានស្តែងឡើងតាមរយៈតួអង្គកូនស្រីយាយតា ដែលជាកូនស្រីម្នាក់មិនយកចិត្តទុកដាក់ ត្រង់ត្រាប់ស្តាប់ដំបូន្មានរបស់ឪពុកម្តាយ។ នាងហ៊ានប្រកែកប្រឆាំងឪពុកម្តាយរហូតតួអង្គស្តេចលែងលះហើយជូននាងឱ្យទៅរស់នៅជាមួយឪពុកម្តាយនាងវិញ។ អាកប្បកិរិយានេះ វាបានបង្ហាញពីការបាត់បង់តម្លៃរបស់ស្ត្រី និងធ្វើឱ្យទំនៀមទម្លាប់ប្រពៃណីដ៏ផូរផង់របស់ខ្មែរ

[៤] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.២៤។

ត្រូវធ្លាក់ចុះ ហើយប្រាសចាកពីសង្គមដែលឱ្យតម្លៃចំពោះស្ត្រី ដែលគេលើកតម្កើងស្ត្រីជាមង្គល។ ដូចមានសេចក្ដីក្នុងដំណើររឿងថា៖ល្ងាចមួយស្ដេចធ្វើជាផឹក ស្រវឹងក្អួតក្អែននៀលពាសពេញផ្ទះ ម្ដាយឱ្យកូនស្រីទៅជូតកំអួតប្ដី តែកូនស្រីមិនទៅជូតឱ្យឡើយ។ ស្ដេចយល់ហេតុការណ៍នេះ ក៏ទៅនិយាយប្រាប់តាយាយតាមដំណើររឿង ឱ្យយាយតាទៅជូនពាក្យកូនក្រមុំគេវិញ។ នៅត្រង់ចំណុចនេះបង្ហាញថា នាងជាកូនមិនទទួលបានសំណាងបានប្ដីជាស្ដេចទេ ព្រោះតែនាងមិនមានសីលធម៌ក្នុងការរួមរស់នៅជាមួយនឹងប្ដីរបស់នាងនោះទេ នាងគ្មានការអត់ធ្មត់ អត់ទ្រាំជាមួយនឹងជីវិតក្រុមគ្រួសារ ទើបស្ដេចលែងលះ។

ចំណែកគុណធម៌វិញ វាគឺជាផ្នែកមួយសំខាន់សម្រាប់មនុស្សម្នាក់ៗក្នុងការរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរ។ គុណធម៌ស្ដែងចេញតាមរយៈកាយ វាចា និងចិត្ត។ គុណធម៌ជួយឱ្យមនុស្សស្គាល់គុណ ស្គាល់ទោស ដឹងអ្វីល្អ អ្វីអាក្រក់ អ្វីខុស អ្វីត្រូវ។ តាមរយៈរឿងមាយើង បានបង្ហាញឱ្យឃើញពីគុណធម៌របស់ស្ត្រីគ្រប់លក្ខណ៍ ដែលចេះអាណិតអាសូរដល់ជនទុគ៌ត ចេះធ្វើបុណ្យដាក់ទានដល់ជនក្រីក្រ។ ដាក់ស្ដែងនៅពេលដែលនាយកេត្រា និងនាងខាតលក្ខណ៍ធ្លាក់ខ្លួនក្រ រហូតដើរសុំទានគេ ហើយបានដើរមកដល់ផ្ទះមាយើង ស្ត្រីគ្រប់លក្ខណ៍ជាប្រពន្ធរបស់មាយើងមានក្ដីអាណិតអាសូរដល់អ្នកសុំទានទាំងពីរនាក់ប្ដីប្រពន្ធ ទាំងមិនទាន់ដឹងថាជាអតីតប្ដីខ្លួន គឺនាយកេត្រា នាងបានដាក់ទានដល់ជនទាំងពីរដោយក្ដីអាណិតមេត្តា។ ដូចមានសេចក្ដីបញ្ជាក់ថា៖ កំសោយកំសត់ ហិនហោចទុគ៌ត ដើរដោយប្រឹថពី ស្វែងរកសុំទាន សព្វឋានទិសទី ចិញ្ចឹមជីវី ជីវិតសព្វថ្ងៃ។ សុំទានរៀងទៅ ដូចដល់លំនៅ ផ្ទះមាយើងនៃ នាងយល់អ្នកខ្សត់ ទុគ៌តក្រក្រៃ ស្មានអ្នកដទៃ ហើយឱ្យទានទៅ។[៥]

តាមរយៈរឿងដើមរលួសមាស ក៏បង្ហាញពីគុណធម៌ដ៏ល្អប្រពៃនៃកុមារីកាផងដែរ។ នាងជានារីដែលពោរពេញដោយគុណធម៌ និងមនុស្សធម៌ នាងតែងតែមាន

[៥] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.៥៣។

ចិត្តមេត្តា ករុណា ចំពោះទុរគតជនទាំងឡាយ នាងមានកតញ្ញូចំពោះម្តាយឪពុកទាំងដែលកំពុងប្រឈមមុខនឹងភាពលំបាកវេទនានៅក្នុងជីវិតយ៉ាងណា ក៏នាងនៅតែតស៊ូ នាងមិនដែលភ្លេចគុណម្តាយ បើទោះបីជាឪពុកនាងមានភរិយាថ្មីក៏នាងនៅមិនស្អប់ខ្ពើម មិនដែលភ្លេចគុណលោកឪពុកនោះទេ។ តួយ៉ាងនាងគ្រាន់តែឃើញឪពុកមកពីធ្វើការ នាងតែងតែគោរពបម្រើលោកជានិច្ច។ ម្យ៉ាងវិញទៀតតួអង្គស្ត្រីដែលជាម្តាយរបស់នាងកុមារីកា មានចិត្តមេត្តាដល់កូន ទោះនាងស្លាប់ទៅហើយ តែនាងនៅតែមានចិត្តស្រឡាញ់ អាណិតសណ្តោសដល់កូន តាមថែរក្សាកូន គឺនាងនៅខំខាំមាត់សង្កត់ចិត្ត តាមចាប់កំណើតជាច្រើនជាតិដើម្បីជួយកូននាង រហូតទាល់តែកូនរបស់គាត់បានក្លាយជាមហេសីស្តេច មានទ្រព្យសម្បត្តិស្តុកស្តម្ភ។ នាងកុមារីកាក៏ដូច្នោះដែរ ពេលដែលខ្លួនមានបាន នាងមិនដែលភ្លេចពីគុណឪពុកម្តាយនោះឡើយ។ បើទោះបីនាងត្រូវមាតាចុង បិតាបង្កើតបណ្តេញចេញពីផ្ទះក៏ដោយ ក៏នាងនៅតែមិនដែលស្អប់បិតា មិនរករឿងមាតាចុង ហើយក៏មិនតាមចងពៀរវេរាអ្វីទៅលើអ្នកទាំងអស់នោះដែរ ដែលនេះជាគុណធម៌មួយដ៏ល្អប្រពៃ ដែលបុត្រធីតាគ្រប់រូបត្រូវតែមាន ដើម្បីជាការតបស្នងសងគុណមាតាបិតា ដែលជាអ្នកមានគុណមកលើបុត្រធីតាទាំងឡាយមិនអាចកាត់ថ្លៃបាន។

### ២.៥-ឧត្តមភាពស្ត្រី ក្នុងការអប់រំបណ្តុះបញ្ញា ឈ្លាសវៃ រឹងមាំ ប៉ិនប្រសប់

សង្គមមួយមានការរីកចម្រើនអាស្រ័យដោយសង្គមនោះសម្បូរទៅដោយធនធានមនុស្សអ្នកមានចំណេះដឹងជ្រៅជ្រះមានបញ្ញាក្នុងការជួយដល់ខ្លួនឯង និងសង្គមជាតិឱ្យមានសេចក្តីរីកចម្រើន។ អាចជួយឱ្យមនុស្សចាកចេញផុតពីឧបសគ្គ ឬបញ្ហាទាំងឡាយដែលកើតមានឡើងនៅក្នុងជីវិត ព្រោះពួកគេបានប្រើប្រាស់បញ្ញាដែលគេមានដើម្បីយកមកដោះស្រាយរាល់បញ្ហា និងឧបសគ្គដែលបានកើតឡើង ប្រកបដោយភាពឈ្លាសវៃ និងប៉ិនប្រសប់។ ការមានប្រាជ្ញាឈ្លាសវៃហាក់បីដូចជាយើងមានអាវុធដ៏មុតស្រួច ដែលអាចឱ្យយើងប្រើប្រាស់ក្នុងការសម្រេចកិច្ចការតូចធំតាមបំណង។ ស្ត្រីដែលមានប្រាជ្ញាឈ្លាសវៃ និងប៉ិនប្រសប់ ជាស្ត្រីដែលត្រូវបានគេឱ្យតម្លៃ និងត្រូវបានបុរសគ្រប់រូបប្រាថ្នាចង់បានជាគូ

ជីវិត។ ស្ត្រីខ្មែរមិនត្រឹមតែមានចរិតទន់ភ្លន់ប៉ុណ្ណោះទេ តែស្ត្រីខ្មែរ គឺមានភាពឈ្លាសវៃប៉ិនប្រសប់ និងពូកែចាត់ចែងគ្រប់កិច្ចការទាំងកិច្ចការងារក្នុងផ្ទះ និងកិច្ចការងារក្រៅផ្ទះ ដែលជាស្ត្រីនាំមកនូវភាពរីកចម្រើនរុងរឿងឱ្យគ្រួសារ ពិសេសគឺស្វាមី។ នៅក្នុងរឿងមាយើង បានបង្ហាញពីភាពឈ្លាសវៃនិងប៉ិនប្រសប់គ្រប់កិច្ចការរបស់ស្ត្រីជាភរិយាក្រោយរបស់ចៅមាណព ដែលពូកែសព្វគ្រប់កិច្ចការទាំងការងារជាស្ត្រីមេផ្ទះទាំងការងារជួយដល់ស្វាមី ដែលជាបុរសកម្សត់ទុគ៌តគ្មានអ្វីទាល់តែសោះ ឱ្យក្លាយជាមនុស្សរីកចម្រើនខ្ពង់ខ្ពស់ប្រកបដោយទ្រព្យសម្បត្តិ កិត្តិយស និងបុណ្យសក្តិ។ ដំបូងឡើយ នាងយកបញ្ញាដោះស្រាយបញ្ហានៅចំពោះមុខបានភ្លាមៗ។ ពេលដែលនាងចុះចេញពីសំពៅមករស់នៅជាមួយចៅមាណព នាងបានបោចស្មៅយកមកចុកកញ្ជើដែលធ្លុះ ដូចក្នុងដំណើររឿងបញ្ជាក់ថា៖ តែស្បៃនៅក នាងដើរចុះមក កាន់ប្តីកំព្រា ទ្រព្យធនពុំយក ជិតមកអាត្មា នាងយោងប្រវា កញ្ជើកាន់ទៅ។[៦]

បុរសមាយើងជាប្តី ជាមនុស្សដែលខ្វះនូវចំណេះដឹង មិនសូវមានប្រាជ្ញា តែដោយសារបានប្រពន្ធក្រោយជាស្ត្រីដែលឆ្លាត និងពូកែ ទើបធ្វើឱ្យគាត់ក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ពោលគឺស្ត្រីជាប្រពន្ធតែងតែចាត់ចែងគ្រប់កិច្ចការសម្រាប់ប្តី មិនថាជាកិច្ចការតូច ឬធំនោះទេ នាងប្រើប្រាស់ភាពឈ្លាសវៃដ៏ប៉ិនប្រសប់របស់នាងសម្រេចបានគ្រប់ភារកិច្ច ក៏ដូចជាជួយយិតយោងស្វាមីឱ្យបានរួចផុតពីទុក្ខលំបាកទាំងឡាយ រហូតក្លាយជាមនុស្សជំនិតរបស់ព្រះមហាក្សត្រ។ ដូចមានសេចក្តីថា៖ ទើបស្តេចគិតគុណក្រៃ ឱ្យយសថ្លៃឥតស្មើឡើយ ដល់មាយើងជាត្រើយ ជាមន្ត្រីធំកន្ទង។ នរសឹងចុះឡើង ចៅមាយើងឥតធ្មឹមផង ហេតុបានភរិយាគ្រង កបលក្ខិណាស្លូតសល់ស្រី។[៧] ក្រៅពីទង្វើនេះ នាងមានបញ្ញា នាងស្គាល់ពីប្រភេទឈើដែលល្អ ដែលមានតម្លៃទើបបង្គាប់ប្តីឱ្យកាប់ឱ្យបានច្រើនដោយនាង

[៦] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.២៣។

[៧] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.៥២។

ជួលរទេះដឹកជញ្ជូនយកមកផ្ទះ ហើយនាងដឹងពីទីផ្សារនៃការលក់ឈើនោះមិនអាចឱ្យពួកឈ្មួញកេងបន្លំបាន ហើយនាងមានបញ្ញាឈ្លាសវៃយល់ដឹងពីស្ថានភាព នាងបានព្យាយាមបង្កើតនូវទំនាក់ទំនងល្អជាមួយពួកមន្ត្រីទាំងឡាយក្នុងរាជវាំង ដើម្បីងាយស្រួលពឹងពាក់ពួកគេឱ្យជួយប្តីរបស់នាងចូលរាជវាំងបម្រើស្តេច។ នាងដឹងមុនថាពេលស្តេចចូលក្នុងព្រៃម្តងៗ ប្រាកដជាគ្មានអ្នកតាមទាន់នោះទេ ទើបមុនចូលវាំង នាងបានបង្ហឹកបង្ហាត់ប្តីនាងឱ្យរត់ឱ្យលឿនទាល់តែលែងដឹងហត់ ហើយនាងបានរៀបចំបាយម្ហូប នំចំណី ស្លាម្លូ ទុកជាស្រេចប្រគល់ឱ្យប្តីថែមទៀត ដោយបម្រុងជាក្រយាសម្រាប់ព្រះរាជា ដែលធ្វើឱ្យព្រះរាជាសព្វព្រះទ័យនឹងប្តីនាងជាពន់ពេក ដែលនេះបញ្ជាក់ពីភាពវៃឆ្លាតរបស់ស្ត្រីគួបផ្សំនឹងការតស៊ូ សាមគ្គីភាព ទើបអាចជួយបុរសៗឱ្យទទួលបានជោគជ័យទៅលើកិច្ចការតូចធំបាន និងមានកិត្តិយស មានទ្រព្យសម្បត្តិស្តុកស្តម្ភ ធ្វើឱ្យគ្រួសាររុងរឿងរីកចម្រើនដោយសារតែភាពឈ្លាសវៃរបស់ស្ត្រី។

យ៉ាងណាមិញនៅក្នុងរឿងប្រវត្តិឃុំវាលដួប បានបង្ហាញឱ្យឃើញពីការប្រើប្រាស់បញ្ញារបស់ស្រីៗក្នុងការដោះស្រាយបញ្ហារបស់ខ្លួនឱ្យចេញផុតពីភាពលំបាក និងដើម្បីទទួលបានភាពជោគជ័យលើបុរស ដោយដឹងថាខ្លួនជាភេទទន់ខ្សោយមិនអាចនឹងយកឈ្នះទៅលើបុរសក្នុងការទាមទារយកឈ្នះលើបុរសក្នុងការធ្វើសន្ធ្រាម ប៉ុន្តែស្រីៗបានប្រើប្រាស់បញ្ញារបស់ខ្លួនដោយឈ្លាសវៃ យកឈ្នះទៅលើបុរសបាន ហើយក៏បានធ្វើឱ្យបុរសៗយកជំនួនទៅជូនខាងស្រីៗតាមការកំណត់។ ស្រីៗបានប្រើបញ្ញាដោយយកស្រាបញ្ឆោកប្រុសៗ ហើយយកកាំបិតសៀតនឹងសក់ ធ្វើជាស្រឡាញ់ប្រុសៗ ធ្វើជាស្រៀវស្រើបសម្រើបតណ្ហា គឺដើម្បីឱ្យបុរសៗទន់ចិត្ត ជឿនិងយល់ច្រឡំថាស្រីៗស្រឡាញ់ខ្លួនពិតប្រាកដ។ លុះពេលល្បួងលោមឱ្យបុរសៗដេកអស់ នាងៗក៏សម្លាប់បុរសៗតែម្តង ពោលគឺស្រីៗអាចមានឱកាសយកឈ្នះបុរសៗបាន បើទោះបីស្រីៗគ្មានកម្លាំងខ្លាំងក៏ពិតមែន តែស្រីៗមានបញ្ញា គឺអាចដោះស្រាយបញ្ហានិងសម្រេចកិច្ចការដែលខ្លួនប៉ងប្រាថ្នាបាន។

បើនិយាយពីភាពរឹងមាំវិញ ថ្វីត្បិតតែស្ត្រីជាភេទដែលមានកម្លាំងទន់ខ្សោយ និងមានចរិតទន់ភ្លន់ក៏ពិតមែន តែស្ត្រីខ្មែរ

មិនទន់ជ្រាយ គឺមានភាពរឹងមាំទាំងផ្លូវកាយ និងផ្លូវចិត្ត ថែមទាំងចេះសម្របខ្លួនបត់បែនទៅតាមកាលៈទេសៈ ទឹកទន្លេក៏ដូចជាស្ថានការណ៍ ឬបញ្ហាដែលខ្លួនជួបប្រទះ។ ជាទូទៅស្ត្រីជួបប្រទះនូវឧបសគ្គច្រើនក្នុងជីវិតប្រចាំថ្ងៃច្រើនជាងបុរស តែស្ត្រីនៅតែអាចបង្ហាញពីភាពរឹងមាំរបស់ខ្លួនដើម្បីដោះស្រាយបានគ្រប់បញ្ហាដែលកើតមាននៅចំពោះមុខ។ ស្ត្រីមានការគិតវែងឆ្ងាយ ហ្មត់ចត់ អត់ធ្មត់ ជាពិសេសស្ត្រីខ្មែរត្រូវបានគេឱ្យតម្លៃថាជាស្ត្រីមានចរិតលក្ខណៈទន់ភ្លន់ តែមិនទន់ជ្រាយ ហើយមានការគិតបានហ្មត់ចត់ និងម៉ឺងម៉ាត់។ យ៉ាងណាមិញរឿង **មាយើង** បានបង្ហាញពីលក្ខណៈសម្បត្តិរបស់ស្ត្រីខ្មែរគ្រប់លក្ខណ៍ដែលជាភរិយាក្រោយរបស់ចៅមាណព ជាស្ត្រីដែលពោរពេញទៅដោយចរិយាសម្បត្តិសមសួន ជាបញ្ចពិធកល្យាណី មានភាពទន់ភ្លន់ រៀបរយ តែរឹងមាំ។ ទោះបីជានាងធ្លាប់ជាប្រពន្ធរបស់នាយគេត្រាដែលជាអ្នកមានទ្រព្យសម្បត្តិ មានអ្នកបម្រើឆ្វេងស្តាំក៏ពិតមែន ប៉ុន្តែពេលដែលនាងបានប្រែក្លាយមកជាភរិយារបស់ចៅមាណពកម្សត់ ក្រីក្រលំបាកនោះ នាងមិនបានចុះចាញ់ មិនខ្លាចនឹងការលំបាកដែលនាងបានជួបប្រទះឡើយ គឺនាងកាន់តែរឹងមាំ នាងតស៊ូព្យាយាមជម្នះ និងសម្របខ្លួនទៅនឹងរឿងរ៉ាវដែលបានកើតឡើងមកលើរូបនាងដោយមិនរុញរា ឬចុះចាញ់នឹងបញ្ហាដែលបានកើតមានចំពោះនាង រហូតនាងបានក្លាយទៅជាអ្នកមានស្តុកស្តម្ភ (ឯនាងភរិយា ចៅនាយគេត្រា ស្តែងស្តាប់សារសេង ប្តីប្តូរផ្តែផ្តាច់ ពាក្យពេចន៍ជាម្តង នាងចរចុះផ្តង ពីលើគេត្រា)[៨]។ នេះបញ្ជាក់ឱ្យឃើញថា នាងជាស្ត្រីគ្រប់លក្ខណ៍ មានភាពរឹងប៉ឹង មាំមួន បត់បែនបានគ្រប់ស្ថានការណ៍ មិនខ្លាចបញ្ហាដែលកើតមានចំពោះនាង ទោះប្តីនាងបានបណ្តេញនាងចុះចេញពីសំពៅ ក៏នាងមិនមានខ្លាចក្នុងការចាកចេញនោះឡើយ។ នាងតស៊ូមោះមុត ប្រឈមមុខនឹងរឿងរ៉ាវដែលកើតឡើង មិនរាថយ និងមិនទន់ជ្រាយ។ ចំណែករឿងប្រវត្តិឃុំវាលជួប ដែលបានបង្ហាញពីភាពអង់អាចក្លាហាន និងរឹងមាំរបស់ស្ត្រីខ្មែរក្នុងការរើបម្រះចេញពីការឱ្យតម្លៃលើប្រុស ដែលស្ត្រីគិតថាជាទំនៀមទម្លាប់មិនស័ក្តិសម មិនគួរគប្បីនឹងបន្តបែបនេះ គឺក្រុមស្ត្រីៗបានប្រើមធ្យោបាយដ៏ឈ្លាសវៃរបស់ខ្លួន គួបផ្សំជាមួយនឹងភាពរឹងមាំរបស់ខ្លួនក្នុងការប្រឆាំងជាមួយទំនៀម

[៨] ពុទ្ធសាសនបណ្ឌិត ***ប្រជុំរឿងព្រេងខ្មែរ ភាគ៤*** រឿងមាយើង ទំ.២៣។

ទម្លាប់នោះ ហើយស្រីៗក៏បានទទួលជោគជ័យ។

## ២.៦. ឧត្តមភាពស្ត្រីតាមរយៈការមានវាចាទន់ភ្លន់ សុភាពរាបសា

ពាក្យសម្ដីគឺមានឥទ្ធិពលខ្លាំងណាស់នៅក្នុងសង្គម។ បុព្វបុរសខ្មែរលោកចាត់ទុកថា "សម្ដីជាឯក លេខជាទោ" និងពាក្យទំនៀមថា "អណ្ដាតជាអាទឹកទន្លង បានសុខទុក្ខផងក៏ព្រោះអណ្ដាត"។ ការពោលពាក្យល្អនាំមកនៅសេចក្ដីសុខ ការពោលពាក្យមិនល្អនាំមកនៅសេចក្ដីទុក្ខ ដែលនេះជាការយល់ឃើញរបស់ខ្មែរ។ ដោយឡែកនៅក្នុងសង្គមខ្មែរ ការផ្ដល់ឧត្តមភាពចំពោះស្ត្រី ក៏បានឆ្លុះបញ្ចាំងតាមរយៈការឱ្យតម្លៃខ្ពស់ទៅលើ បិយវាចានៃស្ត្រីដែរ។ ការមានវាចាទន់ភ្លន់សុភាពរាបសា ត្រូវបានគេចាត់ទុកថាជាស្ត្រីប្រកបដោយលក្ខិណា មានភាពថ្លៃថ្នូរព្រមទាំងទទួលបានការគោរពស្រឡាញ់ និងការកោតសរសើរពីមនុស្សនៅជុំវិញខ្លួន។ ភាពទន់ភ្លន់ សុភាពរាបសារបស់ស្ត្រីជាមន្តស្នេហ៍ដ៏ទាក់ទាញដែលអាចបន្ទន់នូវទឹកចិត្តរបស់មនុស្សទូទៅបាន។

ការផ្ដល់ឧត្តមភាពចំពោះស្ត្រី តាមរយៈការប្រើពាក្យសម្ដីរបស់ស្ត្រីដែលពោលចេញមករមែងតែងមានឥទ្ធិពល ហើយអាចទទួលបានការគាំទ្រ ការផ្ដល់តម្លៃ ក៏ដូចជាការដកស្រង់យកទៅអនុវត្តន៍តាមពីសំណាក់មនុស្សនៅជុំវិញខ្លួន ពោលគឺរវាងបុរសនិងស្ត្រី គេតែងតែឱ្យតម្លៃសម្ដីរបស់ស្ត្រីមានអាទិភាពច្រើន ជាងបុរស។ ជាពិសេសពាក្យសម្ដីដែលស្ត្រីជាម្ដាយ និងជាភរិយាពោលចេញមក គឺមានឥទ្ធិពលខ្លាំងទៅលើបុត្រធីតា និងស្វាមី។ បើម្ដាយពោលពាក្យល្អ កូននឹងបានល្អ បើម្ដាយពោលពាក្យទ្រគោះបោះបោកមិនសមរម្យ ឬហៅថាដេដាក់បណ្ដាសាដល់កូននោះ គេគិតថាវានឹងអាចក្លាយជាការពិត។ ស្វាមីតែងគាំទ្រនិងស្ដាប់តាមមតិយោបល់របស់ភរិយា ដ្បិតជាទូទៅវាចាភរិយា គឺពិតជាមានឥទ្ធិពលខ្លាំងរហូតដល់មានពាក្យពោលថា បើចង់គិតកិច្ចការធំតូចជាមួយនឹងស្វាមីដែលមានឋានៈនោះ គឺគេច្រើនទៅនិយាយកិច្ចការទាំងនោះជាមួយនឹងភរិយាជាមុន បើភរិយាយល់ព្រមមានន័យថាស្វាមីក៏យល់ព្រម ដូចពាក្យគេតែងតែពោលឡើងថា "ប្ដីសក្ដិ៣ ប្រពន្ធសក្ដិ៤" ។ បើនិយាយពីប្រពៃណីទំនៀមទម្លាប់នៃការស្ដីដណ្ដឹងវិញ បើគេចង់ចូលស្ដីដណ្ដឹងកូនក្រមុំនៅផ្ទះណាមួយ បើឪពុកព្រម ម្ដាយ

មិនព្រម គឺស្មើនឹងមិនព្រម បើម្តាយព្រម ឪពុកមិនព្រម គឺនៅតែព្រមដដែល ដូចពាក្យទំនឹមទំនៀមថា"ក្រមុំដណ្តឹងម្តាយ មេម៉ាយដណ្តឹងចិត្ត" ។

តាមរយៈរឿងស្ត្រីពិត ម្តាយពិត ឪពុកពិត បានស្តែងឱ្យឃើញពីអាទិភាពរបស់ពាក្យម្តាយនៅក្នុងគ្រួសារក្នុងការទុកដាក់កូនចៅ គឺសំខាន់និងមានឥទ្ធិពលជាងឪពុក។ ដោយហេតុផលថា ម្តាយជាអ្នកបីបាច់ថ្នាក់ថ្នមកូនច្រើនជាងឪពុក ដូច្នេះពាក្យសម្តីរបស់ម្តាយ គឺត្រូវបានផ្តល់អាទិភាពជាងពាក្យសម្តីរបស់ឪពុក។ នេះបញ្ជាក់ឱ្យឃើញថា ស្ត្រីជាម្តាយមានភាពសំខាន់ជាងឪពុក ម្តាយធំជាងឪពុក ម្តាយមានសិទ្ធិសម្រេចពីអនាគតកូនច្រើនជាងឪពុក។ រីឯនៅក្នុងរឿងគង់ហ៊ាន ក៏បានបង្ហាញឱ្យឃើញពីការឱ្យតម្លៃនៃពាក្យសម្តីរបស់ស្ត្រីដែលមានឥទ្ធិពលចំពោះប្តី។ ក្នុងការសម្រេចចិត្តចាត់ចែងធ្វើការងារដែលព្រះមហាក្សត្របញ្ជាមក។

តម្លៃនៃពាក្យវាចារបស់ស្ត្រី មិនមែនត្រឹមតែជាការឱ្យអាទិភាពតែលើពាក្យសម្តីរបស់ស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែពាក្យសម្តីណាដែលប៉ះពាល់ដល់ស្ត្រី គេតែងហាមប្រាមនិងអប់រំជនានុជន មិនឱ្យប្រើប្រាស់ពាក្យពេចន៍ប្រមាថមើលងាយទៅលើស្ត្រី ព្រោះវានាំឱ្យប៉ះពាល់ដល់ឧត្តមភាពរបស់ស្ត្រី។

នៅក្នុងរឿងមាយើង ក៏បានបង្ហាញពីការឱ្យតម្លៃទៅលើពាក្យពេចន៍វាចារបស់ស្ត្រីដែរ។ ចៅមាយើងបានក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិ និងបុណ្យសក្តិក៏ព្រោះតែស្តាប់តាមប្រពន្ធគ្រប់យ៉ាង ទោះប្រពន្ធឱ្យធ្វើអ្វី ឬទៅណាក៏បុរសជាប្តីមិនដែលប្រកែកតវ៉ា ឬជំទាស់នោះទេ តែងតែស្តាប់និងផ្តល់តម្លៃចំពោះមតិយោបល់របស់ភរិយា ទើបធ្វើឱ្យបុរសនោះរីកចម្រើន (ទើបនាងនារី ស្រដីនឹងប្តី ថាអ្នកសព្វថ្ងៃ ខ្ញុំចង់ឱ្យអ្នក រៀនរត់ឱ្យវៃ ឱ្យរួសឆាប់ក្រៃ ដូចចិត្តចិន្តា។ ក្តីសោតឆ្ងាស់ឆ្លើយ ថាហៃនាងអើយ បងឥតបើថាតាមចិត្តប្អូនហោង អញបងបានជា ម៉្លេះត្បិតនរណា មិនត្បិតប្អូនស្រី។)[៦]

[៦] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.២៧។

សម្តីវាចារបស់មនុស្សស្រី គឺមានឥទ្ធិពលខ្លាំងសម្រាប់ស្វាមី ទោះបីស្វាមីមានចរិតបែបណាក៏ដោយ ឱ្យតែប្រពន្ធចេះប្រើពាក្យពេចន៍ពីរោះពិសាមិនទ្រគោះបោះបោក គ្រួសារនោះនៅតែមានសុភមង្គលរុងរឿង។ តួយ៉ាងដូចជារឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ ជាដើម ទោះបីប្តីជាមនុស្សខ្ជិល មិនធ្វើអ្វីសោះ ក៏នាងជាប្រពន្ធនៅតែប្រើពាក្យពេចន៍ពីរោះ លួងលោម ផ្អែមល្ហែមដាក់ប្តីជានិច្ច មិនដែលនិយាយស្តីឱ្យទាស់ចិត្តប្តីម្តងណាឡើយ ជាហេតុធ្វើឱ្យប្តីដែលខ្ជិលមិនធ្វើអ្វីសោះសុខចិត្តចេញទៅព្រៃកាប់ឈើធ្វើនង្គ័លតាមប្រពន្ធប្រាប់។ ទាំងនេះដោយសារតែនាងជាប្រពន្ធចេះប្រើពាក្យវាចាពីរោះដាក់ប្តី "ខ្ញុំសូមទោសអ្នកប្តី ត្បិតយើងសព្វថ្ងៃក្រណាស់ យើងមិនបានរកស៊ីគ្មានអ្វីទទួលទានទេ សុំឱ្យអ្នកទៅកាប់ឈើធ្វើនង្គ័លរនាស់ធ្វើស្រែនឹងគេ ត្បិតដល់រដូវធ្វើស្រែហើយ"។ ប្តីថា "បើដូច្នេះឱ្យនាងដាំបាយ វេចជាសំណុំចុះ ប្តីនឹងទៅរកកាប់ឈើធ្វើនង្គ័លរនាស់"។[10] ទាំងនេះសរបញ្ជាក់ពីឥទ្ធិពលនៃពាក្យក្យវាចារបស់ស្ត្រី ដែលមានឥទ្ធិពលទៅលើបុរស និងសង្គមគ្រួសារទាំងមូល ពោលគឺទាំងវាចា និងចរិតលក្ខិណារបស់ស្ត្រីគ្រប់លក្ខណ៍ជាភរិយារបស់បុរសកម្ជិល ដែលទន់ភ្លន់ សុភាពរាបសា ទាំងការនិយាយស្តីទាំងសកម្មភាព មិនដែលឱ្យទាស់ចិត្តប្តីម្តងណាឡើយ។ នាងតែងតែពោលពាក្យផ្អែមពីរោះក៏ដូចជាគោរពប្រណិប័តន៍ប្តីបានយ៉ាងល្អ ស័ក្តិសមជាស្ត្រីគ្រប់លក្ខណ៍ឥតមានទាស់ បើទោះបីប្តីជាបុរសនោះខ្ជិលយ៉ាងណា ក៏ស្ត្រីជាភរិយាគោរពប្តី និងប្រើពាក្យទន់ភ្លន់ដាក់ប្តីជានិច្ច។ ការណ៍នេះធ្វើឱ្យគ្រួសាររបស់នាងបានក្លាយជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភដោយសារលក្ខណ៍ស្ត្រីជាភរិយា។

## ២.៧- ឧត្តមភាពស្ត្រីក្នុងការមានភក្តីភាពចំពោះស្វាមី

ភក្តីភាពជាកត្តាសំខាន់ដែលជំរុញឱ្យគ្រួសារមានសេចក្តីសុខ សុភមង្គល និងចម្រុងចម្រើនរុងរឿង។ ភក្តីភាពមានតម្លៃណាស់សម្រាប់មនុស្សម្នាក់ៗពិសេសនៅក្នុងសង្គមគ្រួសារ។ ស្វាមីភរិយាដែលមានភក្តី

[១០] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ២* រឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ ទំ.៩១។

ភាពរវាងគ្នានិងគ្នាតែងតែធ្វើឱ្យគ្រួសារជួបតែសេចក្តីសុខចម្រើនហើយជាទូទៅ ស្ត្រីខ្មែរជាស្ត្រីដែលពោរពេញទៅដោយភក្តីភាពស្មោះត្រង់ចំពោះស្វាមី បើទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

រឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ បានបង្ហាញពីភក្តីភាពរបស់ស្ត្រីគ្រប់លក្ខណ៍ជាកិរិយាដែលមានចិត្តស្មោះស្ម័គ្រចំពោះស្វាមីមិនបែកបែរ ទោះបីជាបុរសជាស្វាមីខ្ជិលច្រអូស មិនធ្វើអ្វីសោះ ហើយគ្រួសារជួបការលំបាក ក៏នាងនៅតែមិនចាកចោលប្តីឡើយ។ រឿងគង់ហ៊ាន តួអង្គ  នាងគំ និងនាងអាំ គឺជាកិរិយាដែលមានភក្តីភាព ស្មោះត្រង់ចំពោះគង់ហ៊ានដែលជាបុរសកំសាក ខ្លាចស្លាប់ គ្មានទំនុកចិត្តនិងទំនួលខុសត្រូវលើខ្លួនឯង និងជាមនុស្សចូលចិត្តអួតក្អេងក្អាង។ ទោះបីជាប្តីរបស់នាងមិនបានសម្លាប់សត្វខ្លា ហើយមិនមានសេចក្តីក្លាហានក្នុងការធ្វើសង្គ្រាម ក៏នាងទាំងពីរនាក់មានទឹកចិត្តសណ្តោស មិនខឹងនឹងប្តី ថែមទាំងចេះលើកទឹកចិត្តប្តីគ្រប់ពេល ចាំជួយបំពេញភារកិច្ចប្តីគ្រប់បែបយ៉ាង ដោយព្រមចេញច្បាំងជាមួយសត្រូវទាំងអស់គ្នារហូតទទួលបានជោគជ័យ។ ភក្តីភាពរបស់ស្ត្រីនេះផងដែរ ក៏បានបង្ហាញតាមរយៈរឿងមាយើង ដែលស្ត្រីគ្រប់លក្ខណ៍បន្ទាប់ពីចាកចេញពីនាយកេត្រាមករស់នៅជាមួយថៅមាណពកាលណា នាងមានចិត្តស្មោះស្ម័គ្រចំពោះថៅមាណព ព្យាយាមជួយជ្រោមជ្រែងថៅមាណពគ្រប់បែបយ៉ាង ទោះបីជាថៅមាណពជាមនុស្សខ្សោយប្រាជ្ញា ក៏នាងស្មោះស្ម័គ្រជួយថៅមាណពជានិច្ច ធ្វើឱ្យគ្រួសារជួបតែសុភមង្គល និងជោគជ័យ។

ជាការពិតណាស់តាមរយៈការសិក្សាលើប្រធានបទមួយនេះចប់សព្វគ្រប់រួចមក យើងខ្ញុំជាអ្នកស្រាវជ្រាវអាចកំណត់បាននូវតម្លៃនៃស្ត្រីខ្មែរដែលឆ្លុះបញ្ចាំងមកក្នុងសង្គមបច្ចុប្បន្នយើងឃើញថាស្ត្រីខ្មែរពិតជាមានតម្លៃមិនអាចខ្វះបានទាំងនៅក្នុងសង្គមគ្រួសារ និងក្នុងសង្គមជាតិ។ មូលហេតុដែលយើងខ្ញុំបានអះអាងថាតម្លៃស្ត្រីពិតជាមិនអាចខ្វះបាន ពីព្រោះថា គ្រប់ការងារទាំងអស់តែងតែមានវត្តមានរបស់ស្ត្រីចូលរួម មិនថាតែការងារតូចធំ ការងារដឹកនាំ  ការងារជំនួញ ការងាររកទទួលទាន ការចិញ្ចឹមបីបាច់ថែរក្សាកូន ការងារគ្រប់គ្រងមើលថែរក្សាទ្រព្យសម្បត្តិ  ការងារជាមន្ត្រី ការងារជា

ច្រើនផ្សេងៗទៀតសុទ្ធតែស្ត្រីអាចធ្វើបានដូចជាបុរសផងដែរ។ បើទោះបីជាតម្លៃស្ត្រីត្រូវបានគេមើលឃើញថាសំខាន់ និងមានតម្លៃយ៉ាងខ្លាំង ក៏ប៉ុន្តែបើយើងវិភាគឱ្យស៊ីជម្រៅទៅយើងក៏អាចមើលឃើញពីផលអវិជ្ជវិជ្ជមានមួយចំនួនដែលស្ត្រីខ្លួនឯងជាអ្នកកំណត់ និងឱ្យតម្លៃ អាស្រ័យដោយសារតែចិត្ត គំនិត និងទង្វើមិនគប្បីមួយចំនួន។ តួយ៉ាងដូចជាការមាក់ងាយប្តី ការដេរប្រទេច ឬប្រើសម្តីមិនគួរគប្បីទៅកាន់មនុស្សនៅជុំវិញខ្លួន។ ការប្រើប្រាស់នូវឥរិយាបថដេក ដើរ ឈរ អង្គុយមិនសម្យរម្យ ការប្រណែនឈ្នានីស្តអ្នកដទៃ ការផិតក្បត់សហាយស្មន់ជាដើម ដែលសកម្មភាពទាំងប៉ុន្មាននេះជាសកម្មភាពដែលស្ត្រីគ្រប់រូបគួរតែពិចារណា និងគួរតែចៀសវាង ដើម្បីចូលរួមចំណែកលើកកម្ពស់តម្លៃស្ត្រីឱ្យកាន់តែមានតម្លៃស្ថិតស្ថេរតរៀងទៅឱ្យមហាជនទូទៅកោតសរសើរ និងចូលរួមថែរក្សានូវរបបមាតាធិបតេយ្យដែលខ្មែរយើងមានការប្រកាន់ភ្ជាប់តាំងពីយូរមកហើយឱ្យបន្តអនុវត្ត គោរព និងថែរក្សាជានិច្ច។

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សា និងវិភាគអំពី "**ឧត្តមភាពស្ត្រីតាមរយៈតំណាលកថាប្រជាប្រិយខ្មែរមួយចំនួន**" រួចមក យើងអាចសន្និដ្ឋានបានថា ស្ត្រីពិតជាមានឧត្តមភាពយ៉ាងខ្លាំងមកលើសង្គមខ្មែរតាំងពីសម័យបុរាណកាលមក និងបានបន្តឥទ្ធិពលមកដល់សម័យបច្ចុប្បន្ននេះ។ តម្លៃស្ត្រីខ្មែរ គឺស្ថិតនៅលើឥរិយាបថនៃការប្រព្រឹត្តប្រកបតាមចរិយាសាស្ត្រនៃស្ត្រីខ្មែរ ដែលប្រកបដោយចរិយាធម៌ មានការប្រព្រឹត្តល្អប្រពៃ មានរបៀបរៀបរយ មានវិន័យ សីលធម៌ល្អ គុណធម៌ សុជីវធម៌ សម្តីសំដៅពីរោះទន់ភ្លន់ កិរិយានៃការប្រព្រឹត្តិ ទាំងកាយវាចា ចិត្ត ប្រកបដោយការគោរព រក្សាបាននូវតម្លៃជាអ្នកម្តាយដ៏ល្អ ដែលជាទីគោរពរបស់កូនៗដ៏ប្រពៃ គោរពប្រណិប័តន៍ តបគុណអ្នកមានគុណដោយមិនឱ្យលោកលំបាក ធ្វើជាម្តាយគំរូ និងជាគរិយាដ៏ល្អសម្រាប់ស្វាមី។ ការរស់នៅរបស់មនុស្សទោះក្នុងគ្រួសារក្តី ក្នុងសង្គមក្តី ទាមទារឱ្យសមាជិកម្នាក់ៗនៃគ្រួសារ ឬសង្គមនោះ មានភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក មិនមានចិត្តរាករេ ផិតក្បត់ កេងប្រវ័ញ្ចគ្នា ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន

ទើបគ្រួសារនោះ ឬសង្គមនោះ អាចមាន សុភមង្គល និងការអភិវឌ្ឍជឿនលឿនបាន។

ឧត្តមភាពស្ត្រីខ្មែរ ស្តែងចេញតាមរយៈ ស្ត្រីទាំងឡាយណាដែលមានការប្រព្រឹត្តដ៏ល្អ មានចរិតឬកពារ កិរិយាមារយាទសុភាពរាបសា រម្យទម ទន់ភ្លន់ ញញឹមញញែម ចេះគោរពសំពះគួរសម ការដែលចេះខិនលំទោន មានរបៀបរៀបរយ ចេះរៀបចំឫកពារ ប្រកបដោយភាពថ្លៃថ្នូរ។ ស្ត្រីដែលសម្តែងអំពីចរិយានៃការប្រព្រឹត្ត ចរិយាដែលមានការគោរព ការទទួលខុសត្រូវលើឥរិយានៃការប្រព្រឹត្តសីលធម៌ សុជីវធម៌ គុណធម៌ មានចិត្តកក្តីភាពដ៏ប្រពៃ គឺជាកិរិយាគំរូ អាចញ៉ាំងគ្រួសារ និងជាតិឱ្យមានការអភិវឌ្ឍរុងរឿងបាន។ គ្រួសារនិងសង្គមជាតិ មានការអភិវឌ្ឍបាន លុះណាតែសមាជិកនៃគ្រួសារ ឬសង្គមនោះមានចិត្តស្មោះត្រង់ និងចេះធ្វើអំពើល្អចំពោះគ្នាទៅវិញទៅមក។ ចំពោះគ្រួសារ ស្វាមីនិងភរិយាគួរតែមានភក្តីភាពរវាងគ្នានិងគ្នា បើប្តីប្រពន្ធមានស្វាមីភក្តិនឹងគ្នា ហើយភាពកក់ក្តៅនឹងកើតមានឡើងដល់បុត្រធីតាទាំងឡាយនិងទទួលបាននូវសេចក្តីរីករាយជាក់ជាពុំខានឡើយ។ ម្យ៉ាងវិញទៀតភក្តីភាពនេះ នឹងនាំឱ្យមាននូវសុភមង្គល គ្រួសារស្ថិតស្ថេរជារៀងរហូត។ សុខភាពផ្លូវកាយ និងផ្លូវចិត្តក៏កើតឡើងព្រោះមិនព្រួយបារម្ភពីការផិតក្បត់គ្នា។ ចំពោះគូស្វាមីណាដែលចេះស្មោះត្រង់នឹងគ្នា គឺជាគំរូដ៏ល្អសម្រាប់គូស្វាមីដទៃទៀតនិងជាគុណធម៌មួយដែលគួរឱ្យគោរពនិងយកតម្រាប់តាម។ មិនតែប៉ុណ្ណោះបើយើងនិយាយពីក្នុងសង្គមគ្រួសារទូទៅ ភក្តីភាពដើរតួនាទីសំខាន់ណាស់ ដើម្បីឱ្យមនុស្សរស់នៅចុះសំរុងនឹងគ្នា និងទុកចិត្តគ្នា ហើយរស់នៅប្រកបដោយសុភមង្គល និងគួរជាទីកោតស្ញប់ស្ញែងនៃមហាជនទាំងឡាយ ហើយនាំឱ្យគ្រួសារនោះមានកិត្តិយសថ្លៃថ្លាជាក់ជាមិនខានឡើយ។ ចំពោះជាតិ ភក្តីភាពនឹងនាំមកនូវភាពរីកចម្រើនលើគ្រប់វិស័យ។ មួយវិញទៀតចំពោះការធ្វើខ្លួនឱ្យក្លាយជាកូនស្រីដ៏ល្អគាប់ប្រសើរនោះយើងឃើញមានរឿងព្រេងមួយចំនួន បានគូសបញ្ជាក់យ៉ាងច្បាស់ថា កូនស្រីដែលមានលក្ខណ៍ល្អ គួរគប្បីគោរពដឹងនូវអនន្តគុណ និងតបគុណចំពោះឪពុកម្តាយដែលជាព្រះរស់របស់ខ្លួន ប្រសិនបើមិនបានតបស្នងសងគុណចំពោះលោកទេ ក៏មិនត្រូវធ្វើឱ្យកេរ្តិ៍ឈ្មោះគ្រួសារអាប់ឱននោះដែរ។ កូនស្រីណាដែលអាច

ប្រកាន់ខ្ជាប់នូវប្រការនេះបាន គេចាត់ទុកថាជាកូនកតញ្ញូ ព្រោះនាងបានរក្សាកិត្តិយសគ្រួសារឱ្យបានគង់វង្ស។ ការប្រកាន់ខ្ជាប់នូវប្រពៃណី ទំនៀមទម្លាប់ឱ្យបានល្អដោយមិនប្រព្រឹត្តហួសគន្លងសីលធម៌ គឺមិនទុំមុនស្រគាល ក៏ជាភារកិច្ចដ៏ចាំបាច់របស់កូនស្រីផងដែរ។

ហេតុនេះកូនស្រីដែលល្អជានិច្ចកាលរមែងតែងនាំមកនូវសិរីសួស្តី និងនាំមកនូវកិត្តិយសឱ្យកើតមានសម្រាប់ក្រុមគ្រួសាររបស់ខ្លួន។ ក្នុងនាមជាអ្នកសិក្សាមួយរូបយើងខ្ញុំពិតជាមាននូវសេចក្តីសោមនស្សរីករាយចំពោះស្នាដៃដ៏វិចិត្ររបស់ដូនតាខ្មែរដែលបានបន្សល់ទុកមកឱ្យសម្រាប់ជាគ្រឿងអបស្នបជីវិតក្នុងដំណើរទៅអនាគត។ ដូច្នេះដើម្បីរក្សានិងលើកតម្កើងនូវតម្លៃស្ត្រី កត្តាដែលចម្បងនោះ គឺការសិក្សា ការថែរក្សាអភិវឌ្ឍន៍ អក្សរសិល្ប៍ជាតិ គឺអាស្រ័យលើមនុស្សជាតិ ជួយជ្រោមជ្រែង រក្សាអភិរក្សអភិវឌ្ឍ ឱ្យស្ថិតស្ថេរគង់វង្សជាអង្វែងតទៅ។

ដោយយើងសង្កេតឃើញថា ឧត្តមភាពស្ត្រីបានផ្សារភ្ជាប់ទៅនឹងវិស័យនានាជាច្រើន ដែលអាចឱ្យយើងមើលឃើញថា សង្គមខ្មែរបានគោរពនិងឱ្យតម្លៃចំពោះស្ត្រីបានដល់កម្រិត រហូតដល់ចាត់ទុកមាតាធិបតេយ្យជាព្រលឹងជាតិមួយក្នុងចំណោមព្រលឹងជាតិជាច្រើនទៀតរបស់ជនជាតិខ្មែរ។ ឧត្តមភាពស្ត្រី ពិតជាបានជះឥទ្ធិពលនៅក្នុងវិស័យនិងផ្នែកជាច្រើនដូចជា ទំនៀមទម្លាប់ប្រពៃណី ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដែលនៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះនៅតែនិយមបន្តប្រើពាក្យ "មេ" ក្នុងវចនសព្ទពាក្យខ្មែរដែលសម្គាល់ភាពជាធំដូចជា មេឃុំ មេភូមិ មេក្រុម មេជាង មេប៉ុស្តិ៍ មេចុងភៅ មេគ្រួសារ មេដឹកនាំ។ល។ ពាក្យទាំងនេះ គឺជាបញ្ញត្តិសម្រាប់សម្គាល់ភាពជាធំ ជាប្រមុខ ជាប្រធានលើសគេដដែល។ បន្ថែមជាងនេះទៅទៀតនោះ ប្រពៃណីទំនៀមទម្លាប់ក្នុងការស្តីដណ្តឹង និងពិធីរៀបអាពាហ៍ពិពាហ៍ ដែលជាអត្តសញ្ញាណជាតិមួយដ៏ផូរផង់របស់ខ្មែរយើង ហើយបន្តប្រព្រឹត្តទៅមកទល់នាពេលបច្ចុប្បន្ននេះ ក៏បានផ្តល់ឧត្តមភាពដល់ស្ត្រីតាមរយៈការរៀបចំជាបណ្ណាការជូនដល់មេបាខាងស្រី ពិធីចូលថែចូវ ពិធីចូលស្តីដណ្តឹង និងរៀបចំពិធីមង្គលការប្រព្រឹត្តទៅនៅគេហដ្ឋានខាងស្រី គឺជាការផ្តល់កិត្តិយសសម្រាប់ស្ត្រី ព្រមទាំងបានក្លាយទៅជាទំនៀមទម្លាប់ និងជា

អត្តសញ្ញាណជាតិមកទល់នឹងពេលបច្ចុប្បន្ន នេះមិនមានការកែប្រែ ឬផ្លាស់ប្តូរអ្វីឡើយ។ កស្តុតាងទាំងអស់នេះបានបង្ហាញយ៉ាង ប្រត្រក្សថា ខ្មែរយើងនៅតែរក្សាឧត្តមភាព ដល់ស្ត្រី។ ទោះបីសម័យបច្ចុប្បន្ននេះ ស្ត្រីខ្លះបានបាត់បង់ឧត្តមភាពរបស់ខ្លួន ដោយសារកត្តាផ្សេងៗក៏ដោយចុះ ប៉ុន្តែនៅក្នុងទឹកចិត្តនៃជនជាតិខ្មែរដែលមានជំនឿ ទៅលើព្រលឹងមាតាធិបតេយ្យនៅតែគោរព ឱ្យតម្លៃទៅលើស្ត្រី និងចាត់ទុកស្ត្រីថាជា អធិបតី ជាមង្គលសម្រាប់គ្រួសារនិងសង្គម។ តំណាលកថាប្រជាប្រិយដែលនិទានតៗគ្នា ពីមាត់មួយទៅមាត់មួយ ពីតំបន់មួយទៅ តំបន់មួយ បានក្លាយជាអត្តសញ្ញាណជាតិខ្មែរមួយ ដែលបានលាតត្រដាងបង្ហាញ ឱ្យឃើញយ៉ាងច្បាស់ពីការផ្តល់ឧត្តមភាព ចំពោះស្ត្រីតាមរយៈការចាត់ទុកស្ត្រីជា អធិបតីមានដូចជា ស្ត្រីក្នុងភាពជាអ្នកដឹកនាំ ស្ត្រីក្នុងការបណ្តុះនូវស្មារតីសន្តិភាព បណ្តុះសីលធម៌-គុណធម៌ បណ្តុះនូវបញ្ញា លក្ខណៈសម្បត្តិរបស់ស្ត្រីខ្មែរ ដែលសក្តិសម ទទួលបានការផ្តល់ឧត្តមភាពពីមនុស្សនៅ ជុំវិញខ្លួន។

ជារួមឧត្តមភាពរបស់ស្ត្រីនៅតែមាន ឥទ្ធិពលតាំងពីសម័យបុរាណកាលរហូតមក ដល់បច្ចុប្បន្ន គឺស្ត្រីជាអ្នកដឹកនាំគ្រួសារនិង សង្គម ពោលគឺស្ត្រីជាឆ្អឹងខ្នងទ្រទ្រង់ដល់ គ្រួសារ និងសង្គមជាតិ ដែលគ្រួសារ និង សង្គមជាតិមិនអាចខ្វះវត្តមានរបស់ស្ត្រីបាន ឡើយ។ ស្ត្រីបានបំពេញតួនាទីជាអ្នករួម ចំណែកនៅក្នុងការធ្វើឱ្យប្រទេសជាតិមាន ភាពរីកចម្រើនរុងរឿង និងអភិវឌ្ឍឈានទៅ មុខ ពិសេសគ្រួសារមានសុខសុភមង្គល មាន ភាពរុងរឿងរីកចម្រើនទៅបានក៏មាន ចំណែករបស់ស្ត្រីជាសំខាន់ផងដែរ សមដូច សុភាសិតថា "**ស្ត្រីជាមាតាពិភពលោក**" និង "**ស្ត្រីជាកម្លាំងចលករដែលសង្គមមិនអាចខ្វះបាន**"។

សូមឱ្យប្រជាជនខ្មែរយើងនៅតែមាន ស្មារតីប្រកាន់ខ្ជាប់នៅក្នុងការផ្តល់តម្លៃ ចំពោះស្ត្រី ដែលជាឧត្តមភាពលើកតម្កើង ស្ត្រីឱ្យសក្តិសមនៅនឹងការលះបង់របស់ស្ត្រី ចំពោះគ្រួសារនិងសង្គម ហើយនៅតែចាត់ ទុកថាជាអត្តសញ្ញាណជាតិតរៀងរហូតទៅ ដោយការផ្តល់តម្លៃដល់ស្ត្រីជាអធិបតីនិងជា មង្គលនៃគ្រួសារ ក៏ដូចជាសង្គមជាតិ៕

# គន្ថនិទ្ទេស


- ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ *ប្រជុំរឿងព្រេងខ្មែរ ភាគ១ ដល់ភាគ៩* គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ភ្នំពេញ ឆ្នាំ២០០១។
- ពុទ្ធសាសនបណ្ឌិត្យ *វចនានុក្រមខ្មែរ* បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧។
- ប៉ិញ ស្រឿន *តម្លៃអប់រំស្ត្រីខ្មែរតាមរយៈសុភាសិតច្បាប់ស្រី របស់អ្នកឧកញ៉ាសុត្តន្តប្រីជាឥន្ទ* ឆ្នាំ២០១៧។
- ស៊ុំ ឈុំឡុង *អក្សរសិល្ប៍ប្រជាប្រិយ* ភ្នំពេញ ឆ្នាំ២០១៥។
- ស៊ុំ ឈុំឡុង *ទស្សនាទានអប់រំសង្គមតាមរយៈតំណាលកថានៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរ* ភ្នំពេញ ឆ្នាំ២០១១។
- ហ៊ុន គឹមសៀ *មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ* ការផ្សាយរបស់បណ្ណាគារភ្នំពេញ ឆ្នាំ១៩៦៣។
- អ៊ីវ ចុង *អក្សរសិល្ប៍ប្រជាប្រិយខ្មែរ* ឆ្នាំ២០១៣។